## ឯកសារទស្សនទាន

# ការសិក្សាស្រាវជ្រាវ ស្តីពី ការប្រែប្រួល និងការឆ្លើយតបនឹងអំពើជួញដូរមនុស្សនៅកម្ពុជា ក្នុងបរិបទកូវីដ១៩ ៖ ផ្តោតលើទស្សនៈយេនឌ័រ

## សាវតា

អស់រយៈពេលជាង២ឆ្នាំមកនេះ ទោះបីជាកម្ពុជាជាប់ដៃប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ ដើម្បីជួយសង្គ្រោះជីវិតប្រជាជនពីវិបត្តិសុខភាពពិភពលោក ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជា នៅតែផ្តល់អាទិភាពខ្ពស់ និងរក្សាសន្ទុះស្មារតី ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសលើស្ត្រីនិងកុមារ ក្នុងគោលបំណងធានាបាននូវការលើកកម្ពស់សិទ្ធិ និងកិច្ចការពារដល់ប្រជាពលរដ្ឋ ដែលសកម្មភាពទាំងនោះរួមមានការងារបង្ការទប់ស្កាត់ ការងារអនុវត្តច្បាប់ យុត្តិធម៌ព្រហ្មទណ្ឌ កិច្ចការពារជនរងគ្រោះ ការងារច្បាប់និងគោលនយោបាយ ការលើកកម្ពស់សិទ្ធិនិងដោះស្រាយបញ្ហាពលករទេសន្តរប្រវេសន៍ និងកិច្ចសហប្រតិបត្តិការ ដោយសម្រេចបានលទ្ធផលគួរឱ្យកត់សម្គាល់។

ទន្ទឹមនឹងសមិទ្ធផលដ៏ត្រចះត្រចង់នេះ ផ្អែកតាមរបាយការណ៍របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានឱ្យដឹងថា ទោះបីជាក្នុងអំឡុងពេលរីករាលដាលខ្លាំងនៃជំងឺកូវីដ១៩ ដែលធ្វើឱ្យចលនាសាកលភាវូបនីយកម្ម សេដ្ឋកិច្ច ពាណិជ្ជកម្ម និងទំនាក់ទំនងដោយផ្ទាល់ក្នុងប្រទេស និងអន្តរជាតិ មានភាពស្ងៀមស្ងាត់ដោយសារវិធានការបង្ការទប់ស្កាត់ជំងឺឆ្លង ដើម្បីការពារអាយុជីវិតប្រជាពលរដ្ឋ ប៉ុន្តែចរន្តនៃអំពើជួញដូរមនុស្ស មិនមានភាពថមថយនោះទេ ផ្ទុយទៅវិញពួកឧក្រិដ្ឋជនកំពុងឆ្លៀតយកឱកាសនេះ ធ្វើសកម្មភាពយ៉ាងផុសផុល និងបានផ្លាស់ប្តូរផ្លូវនិងវិធីសាស្ត្រ ដូចជាការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ដើម្បីអូសទាញ បោកបញ្ឆោតប្រជាពលរដ្ឋដែលងាយរងគ្រោះ សម្រាប់ការជួញដូរ និងកេងប្រវ័ញ្ចជាដើម។ អ្វីជាការកត់សម្គាល់ផងដែរ ក្រៅពីការជួញដូរកម្លាំងពលកម្ម ពិសេសក្នុងចំណោមស្ត្រីកម្មករការងារផ្ទះ ទម្រង់នៃអំពើជួញដូរមនុស្សដែលកំពុងបន្តកើតឡើងរួមមាន អាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ ការពពោះជំនួស ការជួញដូរនិងការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធ Online ជាដើម។ល។

ស្របពេលជាមួយគ្នានេះដែរ ការរីករាលនៃជំងឺកូវីដ១៩ រួមទាំងការដាក់ចេញនូវវិធានការសុខាភិបាល វិធានការរដ្ឋបាល ដើម្បីទប់ស្កាត់ការឆ្លងក្នុងសហគមន៍ ក៏បានជះឥទ្ធិពលដល់ដំណើរការរបស់ប្រតិបត្តិករប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សផងដែរ។

ក្នុងន័យនេះ នាយកដ្ឋានការពារផ្លូវច្បាប់នៃ ក្រសួងកិច្ចការនារី ដែលជាលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (វិស័យសហប្រតិបត្តិការអន្តរជាតិ) និងជាលេខាធិការដ្ឋាននៃក្រុមការងារខមមីតកម្ពុជា ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ កំពុងធ្វើការសិក្សាស្រាវជ្រាវស្តីពី "**ការប្រែប្រួល និងការឆ្លើយតបនឹងអំពើជួញដូរមនុស្ស ក្នុងបរិបទកូវីដ១៩" ដោយផ្អែកលើទស្សនៈយេនឌ័រ ។**

## គោលបំណងនៃការសិក្សាស្រាវជ្រាវ៖

- កំណត់រកចរន្តថ្មីនៃអំពើជួញដូរមនុស្ស និងវិធីសាស្ត្រ (modus operandi) ដែលជនល្មើសជួញដូរកំពុងប្រើប្រាស់ក្នុងបរិបទកូវី១៩ ក្នុងគោលដៅជួញដូរពលរដ្ឋកម្ពុជាជាពិសេសស្ត្រី និងកុមារ។
- ចងក្រងនូវឧត្តមានុវត្តន៍ បញ្ហាប្រឈម និងដំណោះស្រាយ ឆ្លើយតបរបស់ប្រតិបត្តិករប្រយុទ្ធប្រឆាំងជួញដូរមនុស្សក្នុងបរិបទកូវីដ១៩នៅកម្ពុជា
- ស្វែងយល់ពីការអនុវត្តក្របខណ្ឌនៃការគ្រប់គ្រងគ្រោះមហន្តរាយ (Disaster Management Cycle) ដើម្បីធានាប្រសិទ្ធភាពក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅក្នុងអំឡុងនិងក្រោយពេលមានគ្រោះមហន្តរាយ ឬវិបត្តិដោយសារជំងឺឆ្លង ផ្សេងៗនាពេលអនាគត។

លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ នឹងអាចប្រើប្រាស់ជាប្រយោជន៍ក្នុងការដាក់បញ្ចូលទៅក្នុងគោលនយោបាយនិងសកម្មភាពឆ្លើយតបឱ្យកាន់តែសមស្របទៅនឹងបរិការណ៍នៃការរស់នៅ "តាមគន្លងថ្មី (New Normal)" ជាពិសេសឆ្លើយតបនឹងគោលការណ៍យេនឌ័រ និងបរិយាប័ន្ន។

## វិធិសាស្រ្តស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ នឹងអនុវត្តតាមអភិក្រមការសិក្សាស្រាវជ្រាវបែបគុណភាព ដោយប្រើប្រាស់ជំហានទាំង៦ ដូចខាងក្រោម៖

**ជំហានទី១៖** ការសិក្សាស្រាវជ្រាវនេះនឹងធ្វើឡើងតាមរយៈការពិនិត្យឡើងវិញនូវឯកសារដែលមានស្រាប់ដូចជាឯកសារគោលនយោបាយ ផែនការយុទ្ធសាស្ត្រ របាយការណ៍ជាតិ និងអន្តរជាតិដែលពាក់ព័ន្ធនឹងកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីប្រើប្រាស់ជាមូលដ្ឋានក្នុងការស្វែងយល់ទៅលើប្រធានបទនឹងការសិក្សាស្រាវជ្រាវ។

**ជំហានទី២៖** ធ្វើការប្រមូលទិន្នន័យ ពីប្រតិបត្តិករពាក់ព័ន្ធសំខាន់ៗរួមមាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងយុត្តិធម៌ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសុខាភិបាល គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ កាកបាទក្រហមកម្ពុជា គណៈកម្មាធិការជាតិនៃកាកបាទក្រហមអន្តរជាតិហៅកាត់ថា(ICRC) អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ រួមទាំងជនរងគ្រោះដោយអំពើជួញដូរមនុស្សផងដែរ។ *ការប្រមូលទិន្នន័យ នឹងពង្រីកទៅដល់ថ្នាក់ក្រោមជាតិផងដែរ ក្នុងករណីមានធនធាន និងពេលវេលាគ្រប់គ្រាន់។*

**ជំហានទី៣៖** ចងក្រង វិភាគ និងសំយោគទៅលើទិន្នន័យដែលប្រមូលបាន ដើម្បីផ្ទៀតផ្ទាត់សុក្រិត្យភាពនៃការរកឃើញដែលបានមកពីការពិនិត្យលើឯកសារដែលមានស្រាប់ ស្របតាមគោលបំណងរបស់ការសិក្សាស្រាវជ្រាវ

**ជំហានទី៤៖** រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធដើម្បីពិនិត្យលើឯកសារសំយោគលើកទី១

**ជំហានទី៥៖** ពិនិត្យ និងកែសម្រួលផ្អែកតាមធាតុចូលរបស់កិច្ចប្រជុំ

**ជំហានទី៦៖** កិច្ចពិគ្រោះយោបល់ និងផ្ទៀតផ្ទាត់លើលទ្ធផលនៃការសិក្សាស្រាវជ្រាវ លើកចុងក្រោយ

**ជំហានទី៧៖** បោះពុម្ព និងផ្សព្វផ្សាយ